**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ១០៤ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ ដែលសរសេរជាអក្សរកាត់ថា "**ក.ប.ប.**" សម្រាប់ប្រើប្រាស់ក្នុងដំណើរការការងាររបស់អង្គភាព។

## ជំពូកទី២
## ឯកសណ្ឋាន

**មាត្រា២ .-**

ឯកសណ្ឋានរបស់មន្ត្រីរាជការនៃ **ក.ប.ប.** រួមមាន មួក អាវ ខោ សំពត់ ក្រវាត់ក ខ្សែក្រវាត់ ស្បែកជើង និងស្រោមជើង។

**មាត្រា៣ .-**

ខោជើងវែងពណ៌ពងក្រសា ចង្កេះត ថ្នេរបង្កប់ ជីបភ្លីខាងមុខពីរ មានហោប៉ៅបី "ហោប៉ៅមួយនៅខាងក្រោយខាងស្តាំ ដេរបង្កប់ មានគម្របរាងស្លឹកពោធិ៍ និងហោប៉ៅពីរទៀតនៅចំហៀង ដេរបង្កប់តាមថ្នេរ"។

សំពត់ពណ៌ពងក្រសាមានរាងបំពង់តចង្កេះ សម្រុងចុះក្រោមដល់ពាក់កណ្តាលស្មងជើង ផែកខាងក្រោយមានរូតនៅចំហៀង។

ក្រវាត់កពណ៌ទឹកប៊ិកធ្វើពីកំណាត់កូតុង។

ស្បែកជើងមានពីរប្រភេទ មួយប្រភេទសម្រាប់បុរស និងមួយប្រភេទទៀតសម្រាប់នារី។ ស្បែកជើងបុរស កខ្លី ពណ៌ខ្មៅ ចងខ្សែ។ ស្បែកជើងនារី កខ្លី ពណ៌ខ្មៅ មានកែង៣ស.ម.។

ស្រោមជើងពណ៌ខ្មៅធ្វើអំពីកំណាត់កូតុង មានប្រវែងលើភ្នែកគោរ។

ខ្សែក្រវាត់ ខ្សែធ្វើអំពីនីឡុងពណ៌ខ្មៅ ទទឹង២,៨ស.ម. និងមានក្បាលខ្សែក្រវាត់ រាងមូលប៉ោង ធ្វើអំពីស្ពាន់ក្រូមេ ហើយមានពណ៌មាសឬប្រាក់។ ផ្នែកចំកណ្តាលនៃក្បាលខ្សែក្រវាត់ មានរូប រូបសញ្ញានៃ **ក.ប.ប.** មានរាងប៉ោង និងទម្រស្លឹកឈើចំនួនពីរមែកខ្វែងគ្នា។ ក្បាលខ្សែក្រវាត់ពណ៌មាស ត្រូវបានប្រើប្រាស់សម្រាប់ថ្នាក់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងប្រធានសាខា។ ក្បាលខ្សែក្រវាត់ពណ៌ប្រាក់ ត្រូវបានប្រើប្រាស់សម្រាប់ថ្នាក់ប្រធានការិយាល័យ អនុប្រធានសាខា អនុប្រធានការិយាល័យ និងមន្ត្រី។

គំរូខោ សំពត់ ក្រវាត់ក ស្បែកជើង ស្រោមជើង ខ្សែក្រវាត់ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

**មាត្រា៤ .-**

ឯកសណ្ឋានរបស់មន្ត្រីរាជការនៃ **ក.ប.ប.** មានបួនប្រភេទ ដូចខាងក្រោម៖

១. ឯកសណ្ឋានការងារ ប្រើប្រាស់សម្រាប់៖
- បំពេញការងារប្រចាំថ្ងៃនៅក្នុងស្នាក់ការកណ្តាលនិងសាខា
- ចូលរួមប្រជុំការងារ វគ្គបណ្តុះបណ្តាល សិក្ខាសាលា សវនាការតុលាការ និងកម្មវិធីផ្សេងៗ។

២. ឯកសណ្ឋានប្រតិបត្តិការ ប្រើប្រាស់សម្រាប់៖
- បំពេញបេសកកម្មចុះអនុវត្តច្បាប់ក្នុងប្រតិបត្តិការ ឆែកឆេរ ទប់ស្កាត់ និងបង្ក្រាបការក្លែងបន្លំ
- បំពេញការងារត្រួតពិនិត្យទំនិញ សេវា និងចុះអង្កេតទីផ្សារ។

៣. ឯកសណ្ឋានពិធីការ ប្រើប្រាស់សម្រាប់៖
- ចូលរួមព្រះរាជពិធីបុណ្យនិងពិធីបុណ្យជាតិធំៗ
- ចូលរួមសន្និបាតនិងពិធីប្រជុំធំៗ
- ចូលរួមពិធីទទួលភ្ញៀវអន្តរជាតិជាន់ខ្ពស់និងពិធីទស្សនកិច្ចផ្លូវការនៅក្រៅប្រទេស។

៤. អាវក្រៅសម្រាប់មន្ត្រីមន្ទីរពិសោធន៍ ប្រើប្រាស់សម្រាប់៖
- បំពេញការងារក្នុងមន្ទីរពិសោធន៍ នៅស្នាក់ការកណ្តាលនិងសាខា
- បំពេញការងារក្នុងមន្ទីរពិសោធន៍ចល័ត។

**មាត្រា៥ .-**

ឯកសណ្ឋានការងារសម្រាប់មន្ត្រីរាជការនៃ **អ.ប.ប.** ត្រូវបានកំណត់ដូចខាងក្រោម៖

**ក. មួកកាស្កេត**

មួកកាស្កេតត្រូវបានរៀបចំដោយឡែកជា៦ថ្នាក់ខុសៗគ្នា សម្រាប់សម្គាល់ថ្នាក់ ដូចខាងក្រោម៖

**១. ថ្នាក់អគ្គនាយក**

មួកកាស្កេត ធ្វើពីកំណាត់ពណ៌ពងក្រសា ដែលមានផ្នែកខាងមុខលើកណ្ដាប់វណ្ណមានភ្ជាប់រូបព្រះសង្ការពណ៌មាស ទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ការ មានក្បាច់ភ្ញីទេស ប៉ាក់ពណ៌មាស ពីលើកំណាត់ឡែនពណ៌ទឹកប៊ិកជុំវិញ ព្រមទាំងមានខ្សែវណ្ណពណ៌មាស ក្បាច់ត្របកឈូក ភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌មាស នៅចុងទាំងសងខាង។ ខាងក្រោមនៃខ្សែវណ្ណ ផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេសឱនពណ៌មាស ទម្រង់ស្លែងក្របីធំដល់ជើងមួក។

**២. ថ្នាក់អគ្គនាយករង**

មួកកាស្កេត ធ្វើពីកំណាត់ពណ៌ពងក្រសា ដែលមានផ្នែកខាងមុខលើកណ្ដាប់វណ្ណមានភ្ជាប់រូបព្រះសង្ការពណ៌មាស ទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ការ មានខ្សែវណ្ណពណ៌មាស ក្បាច់ត្របកឈូក ភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌មាសនៅចុងទាំងសងខាង។ ខាងក្រោមនៃខ្សែវណ្ណ ផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេសឱនពណ៌មាស ទម្រង់ស្លែងក្របីធំដល់ជើងមួក។

**៣. ថ្នាក់ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងប្រធានសាខា**

មួកកាស្កេត ធ្វើពីកំណាត់ពណ៌ពងក្រសា ដែលមានផ្នែកខាងមុខលើកណ្ដាប់វណ្ណមានភ្ជាប់រូបព្រះសង្ការពណ៌មាស ទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ការ មានកម្រងខ្សែសយពណ៌មាស ភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌មាសនៅចុងទាំងសងខាង។ ខាងក្រោមនៃកម្រងខ្សែសយ ផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេសឱនពណ៌មាស ទម្រង់ស្លែងក្របីធំដល់ជើងមួក។

**៤. ថ្នាក់ប្រធានការិយាល័យនិងអនុប្រធានសាខា**

មួកកាស្កេត ធ្វើពីកំណាត់ពណ៌ពងក្រសា ដែលមានផ្នែកខាងមុខលើកណ្ដាប់វណ្ណមានភ្ជាប់រូបព្រះសង្ការពណ៌ប្រាក់ ទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ការ មានកម្រងខ្សែសយពណ៌ប្រាក់ ភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌ប្រាក់ នៅចុងទាំងសងខាង។ ខាងក្រោមនៃកម្រងខ្សែសយ ផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេសឱនពណ៌ប្រាក់ ទម្រង់ស្លែងក្របីធំទុកចន្លោះ ៤ស.ម. ដល់ជើងមួក។

**៥. ថ្នាក់អនុប្រធានការិយាល័យ**

មួកកាស្កេត ធ្វើពីកំណាត់ពណ៌ពងក្រសា ដែលមានផ្នែកខាងមុខលើកណ្ដាប់វណ្ណមានភ្ជាប់រូបព្រះសង្ការពណ៌ប្រាក់ ទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ការ មានកម្រងខ្សែសយពណ៌ប្រាក់ ភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌ប្រាក់ នៅចុងទាំងសងខាង។ ខាងក្រោមនៃកម្រងខ្សែសយ ផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានផ្កូតពណ៌ប្រាក់ដល់ជើងមួក។

**៦. ថ្នាក់មន្ត្រី**

មួកកាស្កែត ធ្វើពីកំណាត់ពណ៌ពងក្រសា ដែលមានផ្នែកខាងមុខលើកណ្ដាប់វណ្ណមាន ភ្ជាប់រូបព្រះសង្ហារពណ៌ប្រាក់ ទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ហារ មានកម្រងខ្សែសយពណ៌ប្រាក់ ភ្ជាប់ដោយឡេវរូបព្រះសង្ហារពណ៌ប្រាក់ នៅចុងទាំងសងខាង។ ខាងក្រោមនៃកម្រងខ្សែសយ ផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ។

គំរូមួកកាស្កែត ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**ខ. អាវការងារ**

អាវត្រូវបានរៀបចំដោយឡែកជា៣ថ្នាក់ខុសៗគ្នា សម្រាប់សម្គាល់ថ្នាក់ ដូចខាងក្រោម៖

**១. ថ្នាក់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងប្រធានសាខា**

អាវដៃខ្លី មានពណ៌ពងក្រសា កបើក ថ្នេរឌុប ប៉ូលស្មា ជីបចង្កេះ មានហោប៉ៅបួន ហោប៉ៅពីរខាងលើដេរប៉ះ បត់ផ្នត់កណ្ដាល មានគម្របរាងស្លឹកពោធិ៍ ហោប៉ៅផ្ដោកពីរខាងក្រោម ដេរប៉ះមានគម្របរាងស្លឹកពោធិ៍ ឡេវមុខ និងឡេវហោប៉ៅ មានរូបព្រះសង្ហារពណ៌មាស។

**២. ថ្នាក់ប្រធានការិយាល័យ អនុប្រធានសាខា និងអនុប្រធានការិយាល័យ**

អាវដៃខ្លី មានពណ៌ពងក្រសា កបើក ថ្នេរឌុប ប៉ូលស្មា ជីបចង្កេះ មានហោប៉ៅបួន ហោប៉ៅពីរខាងលើដេរប៉ះ បត់ផ្នត់កណ្ដាល មានគម្របរាងស្លឹកពោធិ៍ ហោប៉ៅផ្ដោកពីរខាងក្រោម ដេរប៉ះមានគម្របរាងស្លឹកពោធិ៍ ឡេវមុខ និងឡេវហោប៉ៅ ធម្មតា។

**៣. ថ្នាក់មន្ត្រី**

អាវដៃខ្លី មានពណ៌ពងក្រសា កឌុប ថ្នេរឌុប ចោះឡេវចុងក ប៉ូលស្មា មានហោប៉ៅពីរដេរប៉ះ បត់ផ្នត់កណ្ដាល មានគម្របរាងស្លឹកពោធិ៍ កាត់ស្រុងវែង ជើងត្រង់ដាក់ក្នុងខោ។ ឡេវមុខនិងឡេវហោប៉ៅ ធម្មតា។

គំរូអាវការងារ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ។

**មាត្រា៦ .-**

ឯកសណ្ឋានប្រតិបត្តិការសម្រាប់មន្ត្រីរាជការនៃ **គ.ប.ប.** ត្រូវបានកំណត់ដូចខាងក្រោម៖

**ក. មួកកាតិប**

មួកកាតិបត្រូវបានរៀបចំដោយឡែកជា៤ថ្នាក់ខុសៗគ្នា សម្រាប់សម្គាល់ថ្នាក់ ដូចខាងក្រោម៖

**១. ថ្នាក់អគ្គនាយកនិងអគ្គនាយករង**

- មួកកាតិប(បុរស) ធ្វើពីកំណាត់កូតុងពណ៌ខ្មៅប្រផេះ ដែលមានផ្នែកខាងមុខមានភ្ជាប់រូបព្រះសង្ហារពណ៌មាស មានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាស ទម្រង់ស្នែងក្របីលើក្បាំងដល់ជើងមួក និងមានក្បាំងពណ៌ដូចតួមួក។ ផ្នែកចំហៀងខាងឆ្វេងមានប៉ាក់អក្សរថា "**គ.ប.ប.**" ពណ៌ខៀវ និងផ្នែកចំហៀងខាងស្ដាំ មានប៉ាក់អក្សរឡាតាំងថា "CCF" ពណ៌ខៀវ។
- មួកកាតិប(នារី) ធ្វើពីកំណាត់កូតុងពណ៌ខ្មៅប្រផេះ ដែលមានផ្នែកខាងមុខមានភ្ជាប់រូបព្រះសង្ហារពណ៌មាស មានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាស ទម្រង់ស្នែងក្របីលើក្បាំងដល់ជើងមួក និងមានក្បាំងពណ៌ដូចតួមួក។ ផ្នែកចំហៀងខាងឆ្វេងមានប៉ាក់អក្សរថា "**គ.ប.ប.**" ពណ៌ខៀវ និងផ្នែកចំហៀងខាងស្ដាំ មានប៉ាក់អក្សរឡាតាំងថា "CCF" ពណ៌ខៀវ។

**២. ថ្នាក់ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងប្រធានសាខា**

- មួកកាតិប(បុរស) ធ្វើពីកំណាត់កូតុងពណ៌ខ្មៅប្រផេះ ដែលមានផ្នែកខាងមុខមានភ្ជាប់រូបព្រះសង្ការពណ៌មាស មានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាស ទម្រង់ស្លែងក្របីលើក្បាំង ទុកចន្លោះ២ស.ម. និងមានក្បាំងពណ៌ដូចតួមួក។ ផ្នែកចំហៀងខាងឆ្វេងមានប៉ាក់អក្សរថា "**ក.ប.ប.**" ពណ៌ខៀវ និងផ្នែកចំហៀងខាងស្តាំ មានប៉ាក់អក្សរ ឡាតាំងថា "CCF" ពណ៌ខៀវ។
- មួកកាតិប(នារី) ធ្វើពីកំណាត់កូតុងពណ៌ខ្មៅប្រផេះ ដែលមានផ្នែកខាងមុខមានភ្ជាប់រូបព្រះសង្ការពណ៌មាស មានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាស ទម្រង់ស្លែងក្របីលើក្បាំង ទុកចន្លោះ២ស.ម. និងមានក្បាំងពណ៌ដូចតួមួក។ ផ្នែកចំហៀងខាងឆ្វេងមានប៉ាក់អក្សរថា "**ក.ប.ប.**" ពណ៌ខៀវ និងផ្នែកចំហៀងខាងស្តាំ មានប៉ាក់អក្សរឡាតាំងថា "CCF" ពណ៌ខៀវ។

**៣. ថ្នាក់ប្រធានការិយាល័យនិងអនុប្រធានសាខា**

- មួកកាតិប(បុរស) ធ្វើពីកំណាត់កូតុងពណ៌ខ្មៅប្រផេះ ដែលមានផ្នែកខាងមុខមានភ្ជាប់រូបព្រះសង្ការពណ៌ប្រាក់ មានក្បាច់ភ្ញីទេសប៉ាក់ពណ៌ប្រាក់ ទម្រង់ស្លែងក្របីលើក្បាំង ទុកចន្លោះ២ស.ម. និងមានក្បាំងពណ៌ដូចតួមួក។ ផ្នែកចំហៀងខាងឆ្វេងមានប៉ាក់អក្សរថា "**ក.ប.ប.**" ពណ៌ខៀវ និងផ្នែកចំហៀងខាងស្តាំ មានប៉ាក់អក្សរឡាតាំងថា "CCF" ពណ៌ខៀវ។
- មួកកាតិប(នារី) ធ្វើពីកំណាត់កូតុងពណ៌ខ្មៅប្រផេះ ដែលមានផ្នែកខាងមុខមានភ្ជាប់រូបព្រះសង្ការពណ៌ប្រាក់ មានក្បាច់ភ្ញីទេសប៉ាក់ពណ៌ប្រាក់ ទម្រង់ស្លែងក្របីលើក្បាំង ទុកចន្លោះ២ស.ម. និងមានក្បាំងពណ៌ដូចតួមួក។ ផ្នែកចំហៀងខាងឆ្វេងមានប៉ាក់អក្សរថា "**ក.ប.ប.**" ពណ៌ខៀវ និងផ្នែកចំហៀងខាងស្តាំមានប៉ាក់អក្សរឡាតាំងថា "CCF" ពណ៌ខៀវ។

**៤. ថ្នាក់អនុប្រធានការិយាល័យនិងមន្ត្រី**

- មួកកាតិប(បុរស) ធ្វើពីកំណាត់កូតុងពណ៌ខ្មៅប្រផេះ ដែលមានផ្នែកខាងមុខមានភ្ជាប់រូបព្រះសង្ការពណ៌ប្រាក់ និងមានក្បាំងពណ៌ដូចតួមួក។ ផ្នែកចំហៀងខាងឆ្វេងមានប៉ាក់អក្សរថា "**ក.ប.ប.**" ពណ៌ខៀវ និងផ្នែកចំហៀងខាងស្តាំមានប៉ាក់អក្សរឡាតាំងថា "CCF" ពណ៌ខៀវ។
- មួកកាតិប(នារី) ធ្វើពីកំណាត់កូតុងពណ៌ខ្មៅប្រផេះ ដែលមានផ្នែកខាងមុខមានភ្ជាប់រូបព្រះសង្ការពណ៌ប្រាក់ និងមានក្បាំងពណ៌ដូចតួមួក។ ផ្នែកចំហៀងខាងឆ្វេង មានប៉ាក់អក្សរថា "**ក.ប.ប.**" ពណ៌ខៀវ និងផ្នែកចំហៀងខាងស្តាំមានប៉ាក់អក្សរឡាតាំងថា "CCF" ពណ៌ខៀវ។

គំរូមួកកាតិប ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ។

**ខ. អាវប្រតិបត្តិការ**

អាវដៃវែង មានពណ៌ពងក្រសា កឱប ថ្មេរឱប ចោះឡេវចុងក ប៉ូលស្មា មានហោប៉ៅពីរដេរប៉ះ បត់ផ្នត់កណ្តាល មានគម្របរាងស្លឹកពោធិ៍ កាត់ស្រុងវែង ជើងត្រង់ដាក់ក្នុងខោ។

ចំពោះអាវប្រតិបត្តិការ ត្រូវបានរៀបចំដូចគ្នាទាំងអស់គ្រប់ថ្នាក់។

គំរូអាវប្រតិបត្តិការ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យនេះ។

**គ. អាវក្រៅប្រតិបត្តិការបន្ទាន់**

ប្រភេទអាវដៃវែង ពាក់ខាងក្រៅ ផលិតអំពីសាច់កំណាត់កូតុង មានពណ៌ខៀវប្រផេះ កបើក ថ្នេរឌុប មានឡេវរ៉ូតពីក្រោមហូតដល់លើ ផ្នែកខាងក្រោមមានក្រវាត់ចង្កេះសងខាង និងមានហោប៉ៅបួន (ហោប៉ៅពីរខាងក្រោមដេរបង្កប់តាមថ្នេរ ឆ្វេងមួយ ស្តាំមួយ និងហោប៉ៅពីរទៀតនៅខាងក្នុងអាវផ្នែកមុខ ខាងលើ ឆ្វេងមួយ ស្តាំមួយ)។ ផ្នែកខាងមុខ ខាងស្តាំ និងខាងលើ មានប៉ាក់រូបសញ្ញារបស់ **អ.ប.ប.**។ ផ្នែកខាងក្រោយអាវ មានប៉ាក់អក្សរខ្មែរចំកណ្តាលថា "**អ.ប.ប.**" ពណ៌ខៀវ ។

អាវក្រៅនេះសម្រាប់តែប្រើប្រាស់ក្នុងករណីប្រតិបត្តិការបន្ទាន់។

គំរូអាវក្រៅប្រតិបត្តិការបន្ទាន់ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៦នៃអនុក្រឹត្យនេះ។

**មាត្រា៧ .-**

ឯកសណ្ឋានពិធីការសម្រាប់មន្ត្រីរាជការនៃ **អ.ប.ប.** ត្រូវបានកំណត់ដូចខាងក្រោម៖

**ក. មួកកាស្កែត**

មួកកាស្កែតត្រូវបានរៀបចំដោយឡែកជា៦ថ្នាក់ ខុសៗគ្នា សម្រាប់សម្គាល់ថ្នាក់ ដូចបានរៀបរាប់ក្នុងមាត្រា៥ ចំណុច ក។

**ខ. អាវពិធីការ**

អាវពិធីការប្រើប្រាស់ជាមួយអាវសឺមីដៃវែងពណ៌ស ពាក់ពីខាងក្នុងអាវពិធីការ និងក្រវាត់កពណ៌ទឹកប៊ិក។

អាវពិធីការត្រូវបានរៀបចំដោយឡែកជា២ថ្នាក់ខុសៗគ្នា សម្រាប់សម្គាល់ថ្នាក់ ដូចខាងក្រោម៖

**១. ថ្នាក់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងប្រធានសាខា**

ប្រភេទអាវធំដៃវែង ពណ៌ពងក្រសា កបើក ថ្នេរឌុប ប៉ូលស្មា ដីបក្លីខាងមុខពីរ មានឡេវធំរូបព្រះសង្ការពណ៌មាស ពីក្រោមហូតដល់លើ ហោប៉ៅបួន(ហោប៉ៅពីរ ខាងលើ បត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ ដោយមានឡេវធំរូបព្រះសង្ការពណ៌មាស ហោប៉ៅពីរទៀតនៅក្រោមមានគម្របរាងចតុកោណ ដោយមានឡេវធំរូបព្រះសង្ការពណ៌មាស)។ ផ្នែកខាងក្រោយមានដីបក្លីចំនួនពីរ ឆ្វេងមួយ ស្តាំមួយ និងមានឆែកចំកណ្តាលអាវ។

**២. ថ្នាក់ប្រធានការិយាល័យ អនុប្រធានសាខា អនុប្រធានការិយាល័យ និងមន្ត្រី**

ប្រភេទអាវធំដៃវែង ពណ៌ពងក្រសា កបើក ថ្នេរឌុប ប៉ូលស្មា ដីបក្លីខាងមុខពីរ មានឡេវធំរូបព្រះសង្ការពណ៌ប្រាក់ ពីក្រោមហូតដល់លើ ហោប៉ៅបួន (ហោប៉ៅពីរ ខាងលើ បត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ ដោយមានឡេវធំរូបព្រះសង្ការ ពណ៌ប្រាក់ ហោប៉ៅពីរទៀតនៅក្រោមមានគម្របរាងចតុកោណ ដោយមានឡេវធំរូប ព្រះសង្ការ ពណ៌ប្រាក់)។ ផ្នែកខាងក្រោយមានដីបក្លីចំនួនពីរ ឆ្វេងមួយ ស្តាំមួយ និងមានឆែកចំកណ្តាលអាវ។

គំរូអាវពិធីការ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៧នៃអនុក្រឹត្យនេះ។

**មាត្រា៨ .-**

អាវក្រៅសម្រាប់មន្ត្រីមន្ទីរពិសោធន៍នៃ **អ.ប.ប.** បំពេញការងារនៅមន្ទីរពិសោធន៍ ត្រូវបានកំណត់ដូចខាងក្រោម៖

ប្រភេទអាវដៃវែង សម្រុងត្រឹមក្បាលជង្គង់ សម្រាប់ពាក់ខាងក្រៅ មានពណ៌ស កបើក ថ្នេរឌុប ឡេវខាងមុខមានហោប៉ៅបី "ហោប៉ៅមួយ នៅឆ្វេងដៃខាងលើ និងមានហោប៉ៅពីរនៅខាងក្រោម ត្រឹមចង្កេះ"។ ផ្នែកខាងលើ

នៅខាងស្តាំ មានប៉ាក់រូបសញ្ញា **ក.ប.ប.**។ ខាងក្រោមរូបសញ្ញានេះ មានប៉ាក់អក្សរឡាតាំង CCFTL បញ្ជាក់ពីឈ្មោះមន្ទីរពិសោធន៍។ ផ្នែកខាងក្រោយអាវ មានឆែកចំកណ្តាល។

ស្លាកសម្គាល់ឈ្មោះបំពាក់លើអាវក្រៅសម្រាប់មន្ត្រីមន្ទីរពិសោធន៍ ដូចមានរៀបរាប់ក្នុងមាត្រា៩ ចំណុច ឃ។

គំរូអាវក្រៅសម្រាប់មន្ត្រីមន្ទីរពិសោធន៍ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៨នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## សញ្ញាសម្គាល់

**មាត្រា៩ .-**

សញ្ញាសម្គាល់របស់អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំរួមមាន៖

១- រូបសញ្ញា

រូបសញ្ញារបស់អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ មានរាងមូល និងត្រូវបានកំណត់ដូចខាងក្រោម៖

នៅផ្នែកខាងក្នុងមាន៖

- រូបប្រាសាទអង្គរវត្ត កំពូល៣ និងផែនទីប្រទេសកម្ពុជានៅពីក្រោយ តំណាងឱ្យព្រះរាជាណាចក្រកម្ពុជា
- រូបផែនទីសកលលោក តំណាងឱ្យពាណិជ្ជកម្មអន្តរជាតិ និងកិច្ចការទំនាក់ទំនងអន្តរជាតិក្នុងបរិបទសកលភាវូបនីយកម្ម
- រូបជញ្ជីងពណ៌ទឹកប៊ិក និងមានទ្រនិចពណ៌ក្រហម តំណាងឱ្យអាជ្ញាកណ្តាល ឯករាជ្យ អព្យាក្រឹត្យ និងយុត្តិធម៌
- រូបមីក្រូទស្សន៍សងខាងពណ៌ទឹកប៊ិក តំណាងឱ្យមន្ទីរពិសោធន៍របស់ **ក.ប.ប.**
- រូបដៃសងខាងពណ៌ទឹកប៊ិក តំណាងឱ្យការអនុវត្តច្បាប់ ក្នុងកិច្ចការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ
- អក្សរកាត់ "**ក.ប.ប.**" ពណ៌ក្រហម តំណាងឱ្យអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ
- ផ្កាភ្ញី នៅពីក្រោមអក្សរកាត់ "**ក.ប.ប.**" តំណាងឱ្យរចនាបថខ្មែរ

នៅរង្វង់ខាងក្រៅ រូបខាងលើមាន៖

- ស៊ុមរង្វង់ផ្នែកខាងលើពណ៌ទឹកប៊ិក មានសរសេរអក្សរ "**អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ**" ពណ៌ស និងស៊ុមរង្វង់ផ្នែកខាងក្រោមពណ៌ក្រហម មានអក្សរកាត់ជាភាសាឡាតាំង "CCF" ពណ៌ស អមដោយក្បាច់ផ្កា សងខាងពណ៌ស
- ស៊ុមបន្ទាប់មានពណ៌ស និងរុំព័ទ្ធដោយស៊ុមបញ្ចប់ពណ៌ក្រហម។

គំរូរូបសញ្ញា នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៩នៃអនុក្រឹត្យនេះ។

រូបសញ្ញារបស់អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំនេះត្រូវបានប្រើប្រាស់ដូចខាងក្រោម៖

- ដាក់លើក្បាលលិខិតផ្លូវការរបស់អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ ៕

- ប្រើប្រាស់ក្នុងករណីចាំបាច់ផ្សេងៗដែលបានកំណត់ដោយអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ។

២_ សញ្ញាសម្គាល់

សញ្ញាសម្គាល់សម្រាប់ប្រើប្រាស់ជាមួយឯកសណ្ឋានរបស់មន្ត្រីរាជការនៃ **ក.ប.ប.** ត្រូវបានកំណត់ដូចខាងក្រោម៖

**ក_ ស្លាកសញ្ញាសម្រាប់ពាក់លើចុងកអាវ ឆ្វេង ស្តាំ**

ស្លាកសញ្ញាសម្រាប់ពាក់លើចុងកអាវ ឆ្វេង ស្តាំ មានរាងមូល ទំហំ២,៥ស.ម. និងមានរូបសញ្ញា **ក.ប.ប.** នៅខាងក្នុង រាងប៉ោង និងទម្រស្លឹកឈើចំនួនពីរមែកខ្វែងគ្នា ធ្វើអំពីស្ពាន់ និងក្រូមេពណ៌មាសសម្រាប់ថ្នាក់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានសាខា និងពណ៌ប្រាក់សម្រាប់ថ្នាក់ប្រធានការិយាល័យ អនុប្រធានសាខា អនុប្រធានការិយាល័យ និងមន្ត្រី។

ស្លាកសញ្ញានេះ ប្រើប្រាស់ជាមួយ អាវការងារ អាវប្រតិបត្តិការ និងអាវពិធីការ។

**ខ_ ស្លាកសញ្ញា ក.ប.ប. ដេរភ្ជាប់លើដើមដៃអាវខាងស្តាំ**

ស្លាកសញ្ញា **ក.ប.ប.** ដេរភ្ជាប់លើដើមដៃអាវខាងស្តាំ មានរាងមូល ទំហំបន្ទាត់ផ្ចិត៧ស.ម. ធ្វើអំពីសាច់កំណាត់ ដែលប៉ាក់ដោយកុំព្យូទ័រនិងអំបោះសូត្រ។

ស្លាកសញ្ញា **ក.ប.ប.** ប្រើប្រាស់ជាមួយអាវការងារនិងអាវប្រតិបត្តិការ។

**គ_ ស្លាកសញ្ញា ក្រសួងពាណិជ្ជកម្ម ភ្ជាប់ជាមួយហោប៉ៅអាវខាងលើខាងស្តាំ**

ស្លាកសញ្ញា ក្រសួងពាណិជ្ជកម្ម មានទំហំ៤,៧ស.ម. ធ្វើអំពីស្ពាន់ភ្ជាប់ដោយបន្ទះស្បែក សម្រាប់ព្យួរជាមួយឡេវអាវលើហោប៉ៅអាវខាងលើខាងស្តាំ។

ស្លាកសញ្ញា ក្រសួងពាណិជ្ជកម្ម ប្រើប្រាស់ជាមួយអាវការងារ អាវប្រតិបត្តិការ និងអាវពិធីការ។

**ឃ_ ស្លាកសម្គាល់ឈ្មោះមន្ត្រី ពាក់លើហោប៉ៅអាវខាងលើខាងស្តាំ**

ស្លាកសម្គាល់ឈ្មោះមន្ត្រី មានរាងបួនជ្រុងទ្រវែង ទំហំបណ្តោយ៩ស.ម. ទទឹង២ស.ម. ធ្វើអំពីជាតិជ័ររឹង។ ផ្ទៃខាងក្នុងពណ៌ខៀវទឹកប៊ិក ព័ទ្ធជុំវិញដោយខ្សែបន្ទាត់ពណ៌ស បិទជិត។ ផ្នែកខាងស្តាំ មានរូបសញ្ញា **ក.ប.ប.**។ ផ្នែកខាងឆ្វេងខាងលើ សរសេរឈ្មោះមន្ត្រីរាជការជាអក្សរខ្មែរ។ ផ្នែកខាងឆ្វេងខាងក្រោមសរសេរអត្តលេខមន្ត្រី **ក.ប.ប.** ជាលេខឡាតាំង។

ស្លាកសម្គាល់ឈ្មោះមន្ត្រី ប្រើប្រាស់ជាមួយអាវការងារ អាវប្រតិបត្តិការ អាវពិធីការ និងអាវក្រៅសម្រាប់មន្ត្រីមន្ទីរពិសោធន៍។

គំរូសញ្ញាសម្គាល់ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១០នៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## សញ្ញាសក្តិ

**មាត្រា១០ _**

សញ្ញាសក្តិសម្រាប់ពាក់លើស្មាអាវទាំងសងខាង ត្រូវបានកំណត់ដូចខាងក្រោម៖

- មានបាតក្រោមប្រវែង៦ស.ម.
- បណ្តោយពីលើដល់បាតក្រោមប្រវែង១៣ស.ម.
- ទទឹងមុខកាត់ផ្នែកខាងលើប្រវែង៤,៤០ស.ម. មានរាងកោងជាមុំទាល។

**មាត្រា១១ ._**

សញ្ញាសក្តិ ត្រូវបានរៀបចំដោយឡែកជា៧ថ្នាក់ខុសៗគ្នា សម្រាប់សម្គាល់ថ្នាក់ ដូចខាងក្រោម៖

- ថ្នាក់អគ្គនាយក
- ថ្នាក់អគ្គនាយករង
- ថ្នាក់ប្រធាននាយកដ្ឋាន
- ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានសាខា
- ថ្នាក់ប្រធានការិយាល័យនិងអនុប្រធានសាខា
- ថ្នាក់អនុប្រធានការិយាល័យ
- ថ្នាក់មន្ត្រី។

**១_ ថ្នាក់អគ្គនាយក**

មានផ្ទៃពណ៌ទឹកប៊ិក ក្បាច់ភ្ញីទេស ព័ទ្ធជុំវិញពណ៌មាស នៅផ្នែកខាងក្រោមមានអក្សរ "**អ.ប.ប.**" ពណ៌ទឹកប៊ិក លើផ្ទៃពណ៌មាស នៅពីលើមានរូបចក្រកាំប្រាំបី ចំនួន៤(បួន)គ្រាប់ ពណ៌មាស នៅពីក្រោមរូបសញ្ញារបស់ **អ.ប.ប**. ពណ៌មាសដែលនៅចំកណ្តាល និងមានរូបព្រះសង្ខារពណ៌មាស នៅខាងចុងនៃសញ្ញាសក្តិ និងមានខ្សែព្ធួរវេញមួយខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។

**២_ ថ្នាក់អគ្គនាយករង**

មានផ្ទៃពណ៌ទឹកប៊ិក ក្បាច់ភ្ញីទេស ព័ទ្ធជុំវិញពណ៌មាស នៅផ្នែកខាងក្រោមមានអក្សរ "**អ.ប.ប.**" ពណ៌ទឹកប៊ិក លើផ្ទៃពណ៌មាស នៅពីលើមានរូបចក្រកាំប្រាំបី ចំនួន៣(បី)គ្រាប់ ពណ៌មាស នៅពីក្រោមរូបសញ្ញារបស់ **អ.ប.ប**. ពណ៌មាសដែលនៅចំកណ្តាល និងមានរូបព្រះសង្ខារពណ៌មាស នៅខាងចុងនៃសញ្ញាសក្តិ និងមានខ្សែព្ធួរវេញមួយខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។

**៣_ ថ្នាក់ប្រធាននាយកដ្ឋាន**

មានផ្ទៃពណ៌ទឹកប៊ិក ក្បាច់ភ្ញីទេស ព័ទ្ធជុំវិញពណ៌មាស នៅផ្នែកខាងក្រោមមានអក្សរ "**អ.ប.ប.**" ពណ៌ទឹកប៊ិក លើផ្ទៃពណ៌មាស នៅពីលើមានរូបចក្រកាំប្រាំបី ចំនួន២(ពីរ)គ្រាប់ ពណ៌មាស នៅពីក្រោមរូបសញ្ញារបស់ **អ.ប.ប**. ពណ៌មាសដែលនៅចំកណ្តាល និងមានរូបព្រះសង្ខារពណ៌មាស នៅខាងចុងនៃសញ្ញាសក្តិ និងមានខ្សែព្ធួរវេញមួយខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។

**៤_ ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានសាខា**

មានផ្ទៃពណ៌ទឹកប៊ិក ក្បាច់ភ្ញីទេស ព័ទ្ធជុំវិញពណ៌មាស នៅផ្នែកខាងក្រោមមានអក្សរ "**អ.ប.ប.**" ពណ៌ទឹកប៊ិក លើផ្ទៃពណ៌មាស នៅពីលើមានរូបចក្រកាំប្រាំបី ចំនួន១(មួយ)គ្រាប់ ពណ៌មាស នៅពីក្រោមរូបសញ្ញារបស់ **អ.ប.ប**. ពណ៌មាសដែលនៅចំកណ្តាល និងមានរូបព្រះសង្ខារពណ៌មាស នៅខាងចុងនៃសញ្ញាសក្តិ និងមានខ្សែព្ធួរវេញមួយខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។

**៥_ ថ្នាក់ប្រធានការិយាល័យនិងអនុប្រធានសាខា**

មានផ្ទៃពណ៌ទឹកប៊ិក ក្បាច់ភ្ញីទេស ព័ទ្ធជុំវិញពណ៌ប្រាក់ នៅផ្នែកខាងក្រោមមានអក្សរ "**អ.ប.ប.**" ពណ៌ទឹកប៊ិក លើផ្ទៃពណ៌ប្រាក់ នៅពីលើមានរូបចក្រកាំប្រាំបី ចំនួន៣(បី)គ្រាប់ ពណ៌ប្រាក់ នៅពីក្រោមរូបសញ្ញារបស់ **អ.ប.ប**. ពណ៌ប្រាក់ដែលនៅចំកណ្តាល និងមានរូបព្រះសង្ខារពណ៌ប្រាក់ នៅខាងចុងនៃសញ្ញាសក្តិ និងមានខ្សែព្ធួរវេញមួយខ្សែពណ៌ប្រាក់ព័ទ្ធជុំវិញខាងក្រៅ។

**៦_ ថ្នាក់អនុប្រធានការិយាល័យ**

មានផ្ទៃពណ៌ទឹកប៊ិក ក្បាច់ភ្ញីទេស ព័ទ្ធជុំវិញពណ៌ប្រាក់ នៅផ្នែកខាងក្រោមមានអក្សរ "**អ.ប.ប.**" ពណ៌ទឹកប៊ិក លើផ្ទៃពណ៌ប្រាក់ នៅពីលើមានរូបចក្រកាំប្រាំបី ចំនួន២(ពីរ)គ្រាប់ ពណ៌ប្រាក់ នៅពីក្រោមរូបសញ្ញារបស់ **អ.ប.ប.** ពណ៌ប្រាក់ដែលនៅចំកណ្តាល និងមានរូបព្រះសង្ការពណ៌ប្រាក់ នៅខាងចុងនៃសញ្ញាសក្តិ និងមានខ្សែព្ធរវេញមួយខ្សែពណ៌ប្រាក់ព័ទ្ធជុំវិញខាងក្រៅ។

**៧_ ថ្នាក់មន្ត្រី**

មានផ្ទៃពណ៌ទឹកប៊ិក ក្បាច់ភ្ញីទេស ព័ទ្ធជុំវិញពណ៌ប្រាក់ នៅផ្នែកខាងក្រោមមានអក្សរ "**អ.ប.ប.**" ពណ៌ទឹកប៊ិក លើផ្ទៃពណ៌ប្រាក់ នៅពីលើមានរូបចក្រកាំប្រាំបី ចំនួន១(មួយ)គ្រាប់ ពណ៌ប្រាក់ នៅពីក្រោមរូបសញ្ញារបស់ **អ.ប.ប.** ពណ៌ប្រាក់ដែលនៅចំកណ្តាល និងមានរូបព្រះសង្ការពណ៌ប្រាក់ នៅខាងចុងនៃសញ្ញាសក្តិ និងមានខ្សែព្ធរវេញមួយខ្សែពណ៌ប្រាក់ព័ទ្ធជុំវិញខាងក្រៅ។

គំរូសញ្ញាសក្តិ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១១នៃអនុក្រឹត្យនេះ។

## ជំពូកទី៥
## ការផ្តល់ ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ

**មាត្រា១២ .-**

មន្ត្រីរាជការនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំត្រូវទទួលបាននូវរបបឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ដូចបានកំណត់ក្នុងអនុក្រឹត្យនេះ ជារៀងរាល់ឆ្នាំ តាមថ្នាក់របស់មន្ត្រីម្នាក់ៗ និងការកំណត់ដូចខាងក្រោម៖

- មួកកាស្កេតមួយនិងមួកកាតិបមួយ
- សញ្ញាសម្គាល់មួយឈុត
- សញ្ញាសក្តិមួយគូ
- ខោឬសំពត់ពីរ
- អាវការងារមួយ
- អាវប្រតិបត្តិការមួយ
- អាវក្រៅប្រតិបត្តិការបន្ទាន់មួយ
- អាវពិធីការមួយ
- អាវក្រៅសម្រាប់មន្ត្រីមន្ទីរពិសោធន៍មួយ
- ស្បែកជើងបុរសឬនារីមួយគូ និងស្រោមជើងពីរគូ
- ក្រវ៉ាត់កមួយ
- ខ្សែក្រវ៉ាត់មួយ។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**មាត្រា១៣ .-**

ជនណាដែលក្លែងបន្លំ ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ឬក្លែងបន្លំខ្លួនដោយស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការនៃ **អ.ប.ប.** ដូចបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា១៤ .-**

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ដែលអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំកំពុងប្រើប្រាស់បច្ចុប្បន្ន ត្រូវបន្តហូតដល់មានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិថ្មីមកជំនួស។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា១៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ១១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ២០២០
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០២០**

**ស្តីពី "ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ"**

## គំរូខោ សំពត់ ក្រវាត់ក ស្បែកជើង ស្រោមជើង ខ្សែក្រវាត់

ខោ



ពីមុខ



ពីក្រោយ

សំពត់



ពីមុខ



ពីក្រោយ

ក្រវាត់ក



ស្រោមជើង



**គំរូខោ សំពត់ ក្រវាត់ក ស្បែកជើង ស្រោមជើង ខ្សែក្រវាត់**

ស្បែកជើងសម្រាប់បុរស



ស្បែកជើងសម្រាប់នារី



ក្បាលខ្សែក្រវាត់ ពណ៌មាស
(ថ្នាក់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន
អនុប្រធាននាយកដ្ឋាន និងប្រធានសាខា)



ក្បាលខ្សែក្រវាត់ ពណ៌ប្រាក់
(ថ្នាក់ប្រធានការិយាល័យ អនុប្រធានសាខា
អនុប្រធានការិយាល័យ និងមន្ត្រី)



## ឧបសម្ព័ន្ធទី២

**នៃអនុក្រឹត្យលេខ** ១០៤ អនក្រ.បក **ចុះថ្ងៃទី** ១៦ **ខែ** កក្កដា **ឆ្នាំ២០២០**

**ស្តីពី "ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការ**

**នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ"**

### គំរូមួកកាស្កេត

១. ថ្នាក់អគ្គនាយក



២. ថ្នាក់អគ្គនាយករង



៣. ថ្នាក់ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងប្រធានសាខា



៤. ថ្នាក់ប្រធានការិយាល័យនិងអនុប្រធានសាខា



៥. ថ្នាក់អនុប្រធានការិយាល័យ



៦. ថ្នាក់មន្ត្រី



## ឧបសម្ព័ន្ធទី៣

**នៃអនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០២០**

**ស្ដីពី "ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ"**

### គំរូអាវការខារ

១. ថ្នាក់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងប្រធានសាខា



ពីមុខ ពីក្រោយ

២. ថ្នាក់ប្រធានការិយាល័យ អនុប្រធានសាខា និងអនុប្រធានការិយាល័យ



ពីមុខ ពីក្រោយ

## គំរូអាវការងារ

៣. ថ្នាក់មន្ត្រី



ពីមុខ ពីក្រោយ

## ឧបសម្ព័ន្ធទី៤

**នៃអនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០២០**

**ស្តីពី "ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការ**

**នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ"**

### គំរូមួកកាតិប

១. ថ្នាក់អគ្គនាយកនិងអគ្គនាយករង

(សម្រាប់បុរស) (សម្រាប់នារី)






២. ថ្នាក់ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងប្រធានសាខា

(សម្រាប់បុរស) (សម្រាប់នារី)






## គំរូមួកភាគិច

៣. ថ្នាក់ប្រធានការិយាល័យនិងអនុប្រធានសាខា

(សម្រាប់បុរស)



(សម្រាប់នារី)




៤. ថ្នាក់អនុប្រធានការិយាល័យនិងមន្ត្រី

(សម្រាប់បុរស)



(សម្រាប់នារី)



## ឧបសម្ព័ន្ធទី៥

**នៃអនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០២០**

**ស្តីពី "ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការ**
**នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ"**

### គំរូអាវប្រតិបត្តិការ



ពីមុខ ពីក្រោយ

**ឧបសម្ព័ន្ធទី៦**

**នៃអនុក្រឹត្យលេខ**១០៤ អនក្រ.បក....**ចុះថ្ងៃទី**១៦.....**ខែ**កក្កដា.......**ឆ្នាំ២០២០**

**ស្តីពី "ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការ**

**នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ"**

**គំរូអាវក្រៅប្រតិបត្តិការបន្ទាន់**



ពីមុខ ពីក្រោយ

## ឧបសម្ព័ន្ធទី៧

នៃអនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០២០

ស្តីពី "ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការ

នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ"

### គំរូអាវពិធីការ

១. ថ្នាក់អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងប្រធានសាខា



ពីមុខ ពីក្រោយ

២. ថ្នាក់ប្រធានការិយាល័យ អនុប្រធានសាខា អនុប្រធានការិយាល័យ និងមន្ត្រី



ពីមុខ ពីក្រោយ

## ឧបសម្ព័ន្ធទី៨

**នៃអនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០២០**

**ស្ដីពី "ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការ**
**នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ"**

**គំរូអាវក្រៅសម្រាប់មន្ត្រីមន្ទីរពិសោធន៍**



**ឧបសម្ព័ន្ធទី៩**

**នៃអនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០២០**

**ស្តីពី "ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការ**
**នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ"**

**គំរូរូបសញ្ញា**
**នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ**

**ឧបសម្ព័ន្ធទី១០**

**នៃអនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០២០**

**ស្តីពី "ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ"**

**គំរូសញ្ញាសម្គាល់**

គំរូស្លាកសញ្ញាសម្រាប់ពាក់
លើចុងកអាវ ឆ្វេង ស្តាំ

សម្រាប់ថ្នាក់ អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងប្រធានសាខា




សម្រាប់ថ្នាក់ ប្រធានការិយាល័យ អនុប្រធានសាខា អនុប្រធានការិយាល័យ និងមន្ត្រី




គំរូស្លាកសញ្ញា ក្រសួងពាណិជ្ជកម្ម
ភ្ជាប់ជាមួយហោប៉ៅអាវ ខាងលើ ខាងស្តាំ




គំរូស្លាកសម្គាល់ឈ្មោះមន្ត្រី
ពាក់លើហោប៉ៅអាវ ខាងលើ ខាងស្តាំ






**ឧបសម្ព័ន្ធទី១១**

**នៃអនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០២០**

**ស្តីពី "ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីរាជការ**

**នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ"**

**គំរូសញ្ញាសក្តិ**

១. ថ្នាក់អគ្គនាយក



២. ថ្នាក់អគ្គនាយករង



៣. ថ្នាក់ប្រធាននាយកដ្ឋាន



៤. ថ្នាក់អនុប្រធាននាយកដ្ឋាន និងប្រធានសាខា




៥. ថ្នាក់ប្រធានការិយាល័យ និងអនុប្រធានសាខា




៦. ថ្នាក់អនុប្រធានការិយាល័យ




៧. ថ្នាក់មន្ត្រី

